# សុន្ទរកថាស្វាគមន៍
# និងរបាយការណ៍ស្តីពីការងារបរិស្ថានឆ្នាំ២០១៦

## ឯកឧត្តម សាយ សំអាល់ រដ្ឋមន្ត្រីក្រសួងបរិស្ថាន និងជា
## ប្រធានក្រុមប្រឹក្សាជាតិដោយអភិវឌ្ឍន៍ដោយចីរភាព
## ក្នុងពិធីបើក«សន្និបាតបូកសរុបលទ្ធផលការងារបរិស្ថានឆ្នាំ២០១៦ និង
## ទិសដៅការងារឆ្នាំ២០១៧»

រាជធានីភ្នំពេញ ថ្ងៃទី២១ ខែធ្នូ ឆ្នាំ២០១៦

- *ជាបឋម ខ្ញុំបាទសូមគោរពឯកឧត្តម ប៊ិន ឈិន ឧបនាយករដ្ឋមន្ត្រីប្រចាំការ និងជាប្រធានអាជ្ញាធរជាតិដោះស្រាយទំនាស់ដីធ្លី តំណាងដ៏ខ្ពង់ខ្ពស់ សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា ជាទីគោរពដ៏ខ្ពង់ខ្ពស់!*
- *សូមគោរព ឯកឧត្តម លោកជំទាវ ប្រធានគណៈកម្មការនៃព្រឹទ្ធសភា និងរដ្ឋសភា ដ៏ឧត្តុង្គឧត្តម*
- *ឯកឧត្តម លោកជំទាវ លោក លោកស្រី ថ្នាក់ដឹកនាំ មន្ត្រីរាជការ នៃក្រសួងបរិស្ថាន តំណាងក្រសួង ស្ថាប័ន រដ្ឋបាលថ្នាក់ក្រោមជាតិ ដៃគូអភិវឌ្ឍន៍ និងវិស័យឯកជន*
- *លោក លោកស្រី ភ្ញៀវកិត្តិយសទាំងអស់ ជាទីមេត្រី!*

ថ្ងៃនេះ យើងខ្ញុំទាំងអស់គ្នាជាថ្នាក់ដឹកនាំ និងមន្ត្រីរាជការនៃក្រសួងបរិស្ថានមានកិត្តិយស និងសេចក្តីសោមនស្សរីករាយឥតឧបមា សូមសម្តែងនូវបដិសណ្ឋារកិច្ច និងការស្វាគមន៍យ៉ាងកក់ក្តៅបំផុតជូនចំពោះ **ឯកឧត្តម ប៊ិន ឈិន** ឧបនាយករដ្ឋមន្ត្រីប្រចាំការ និងជាប្រធានអាជ្ញាធរជាតិដោះស្រាយទំណាស់ដីធ្លី តំណាងដ៏ខ្ពង់ខ្ពស់ **សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា** ដែលបានផ្តល់កិត្តិយសអញ្ជើញជាអធិបតីក្នុងពិធីបើក «សន្និបាតបូកសរុបលទ្ធផលការងារបរិស្ថានឆ្នាំ២០១៦ និងទិសដៅការងារឆ្នាំ២០១៧» នាពេលនេះ។ វត្តមានដ៏ថ្លៃថ្លារបស់ឯកឧត្តមរដ្ឋមន្ត្រីពិតជាញ៉ាំងឱ្យពិធីនេះកាន់តែមានភាពអធឹកអធម និងអត្ថន័យថែមទៀត។

ទន្ទឹមនឹងនេះ យើងខ្ញុំក៏សូមស្វាគមន៍យ៉ាងកក់ក្តៅ និងថ្លែងអំណរគុណយ៉ាងជ្រៀលជ្រៅចំពោះឯកឧត្តម លោកជំទាវជាប្រធានគណៈកម្មការនៃព្រឹទ្ធសភា និងរដ្ឋសភា ឯកឧត្តម លោកជំទាវ លោក លោកស្រី ជាតំណាងក្រសួង ស្ថាប័ន រដ្ឋបាលថ្នាក់ក្រោមជាតិ ដៃគូអភិវឌ្ឍន៍ វិស័យឯកជន និងភ្ញៀវកិត្តិយសជាតិ និងអន្តរជាតិទាំងអស់ ដែលបានឆ្លៀតពេលវេលាដ៏មមាញឹក និងមានតម្លៃអញ្ជើញចូលរួមសន្និបាតនេះ។

- *ឯកឧត្តមឧបនាយករដ្ឋមន្ត្រីជាទីគោរពដ៏ខ្ពង់ខ្ពស់!*
- *ឯកឧត្តម លោកជំទាវ លោក លោកស្រី និងអង្គពិធីទាំងមូលជាទីគោរពរាប់អាន!*

ក្រសួងបរិស្ថានរៀបចំសន្និបាតប្រចាំឆ្នាំនាពេលនេះគឺដើម្បីធ្វើការត្រួតពិនិត្យ និងវាយតម្លៃលើលទ្ធផលការងារបរិស្ថាន ដែលក្រសួងសម្រេចបានក្នុងឆ្នាំ២០១៦កន្លងទៅ បញ្ហាប្រឈម ដំណោះស្រាយ ព្រមទាំងលើកទិសដៅការងារអាទិភាពសម្រាប់ឆ្នាំ២០១៧ ជាពិសេសក្នុងន័យឆ្លើយតបទៅនឹងអនុសាសន៍ដ៏ថ្លៃថ្លារបស់ **សម្តេចអគ្គមហាសេនាបតីតេជោនាយករដ្ឋមន្ត្រី** ថ្លែងនៅក្នុងឱកាសសម្ពោធ «អគារមរតកតេជោ» និងពិធីបើកសន្និបាតបូកសរុបលទ្ធផលការងារបរិស្ថានឆ្នាំ២០១៥ និងទិសដៅការងារឆ្នាំ២០១៦ កាលពីខែកុម្ភៈ ឆ្នាំ២០១៦។ សន្និបាតនឹងប្រព្រឹត្តទៅរយៈពេលបីថ្ងៃ ចាប់ពីថ្ងៃទី២១ ដល់ថ្ងៃទី២៣ ខែធ្នូ ឆ្នាំ២០១៦ ដោយមានអ្នកចូលរួម

សរុបប្រមាណ ៦០០ នាក់ មកពីព្រឹទ្ធសភា រដ្ឋសភា ក្រសួង ស្ថាប័នរដ្ឋ ដៃគូអភិវឌ្ឍន៍ អង្គការជាតិ-អន្តរជាតិ វិស័យឯកជន និងអ្នកពាក់ព័ន្ធ។

ឆ្លៀតឱកាសនេះ ខ្ញុំសូមជម្រាបជូន**ឯកឧត្តមឧបនាយករដ្ឋមន្ត្រី** និងអង្គសន្និបាតមេត្តាជ្រាបថា ដោយផ្អែកលើយុទ្ធសាស្ត្រចតុកោណដំណាក់កាលទី៣ របស់រាជរដ្ឋាភិបាល ជាពិសេស មតិណែនាំដ៏ខ្ពង់ខ្ពស់របស់សម្តេចតេជោនាយករដ្ឋមន្ត្រី ក្នុងកិច្ចប្រជុំពេញអង្គលើកទី១ របស់គណៈរដ្ឋមន្ត្រី កាលពីថ្ងៃទី២៥ ខែកញ្ញា ឆ្នាំ២០១៣កន្លងទៅ ក្រសួងបរិស្ថានបានកំណត់គោលដៅជាយុទ្ធសាស្ត្រចំនួន៤គឺ ការធ្វើទំនើបកម្មស្ថាប័ន កិច្ចគាំពារបរិស្ថាន ការអភិរក្សជីវៈចម្រុះ និងការរស់នៅដោយចីរភាព មកធ្វើជាមូលដ្ឋានគ្រឹះ ដើម្បីតម្រង់ទិសដល់ការរៀបចំគោលនយោបាយ ផែនការយុទ្ធសាស្ត្រ និងផែនការសកម្មភាពសម្រាប់វិស័យបរិស្ថាន និងធនធានធម្មជាតិ សំដៅធានាឱ្យបាននូវតុល្យភាពរវាង «**ការអភិរក្ស និងការអភិវឌ្ឍ**» ស្របតាមផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ និងគោលដៅអភិវឌ្ឍន៍ដោយចីរភាព (Sustainable Development Goals-SDG)។

ដើម្បីសម្រេចគោលដៅជាយុទ្ធសាស្ត្រដែលបានកំណត់ ក្រសួងបរិស្ថានបានខិតខំប្រឹងប្រែងអនុវត្តការងារចម្បងៗក្នុងវិស័យបរិស្ថាន និងធនធានធម្មជាតិ ដោយគិតត្រឹមចុងខែធ្នូ ឆ្នាំ២០១៦នេះ ទទួលបានលទ្ធផលសំខាន់ៗ ដូចខាងក្រោម៖

**១. ការធ្វើទំនើបកម្មស្ថាប័ន៖** ដើម្បីជាមូលដ្ឋានសម្រាប់ទ្រទ្រង់ដល់ការបំពេញភារកិច្ចស្នូលរបស់ខ្លួនពាក់ព័ន្ធនឹងកិច្ចគាំពារបរិស្ថាន ការគ្រប់គ្រងធនធានធម្មជាតិ ការអភិរក្សជីវៈចម្រុះ និងការអភិវឌ្ឍដោយចីរភាព ក្រសួងបរិស្ថានបានធ្វើទំនើបកម្មស្ថាប័ន ដោយផ្តោតការយកចិត្តទុកដាក់លើការងារជាអាទិភាពដូចខាងក្រោម៖

- យកចិត្តទុកដាក់ក្នុងការធ្វើទំនើបកម្មស្ថាប័នចាប់តាំងពីដើមអាណត្តិទី៥នេះ ដោយចាប់ផ្តើមគិតគូរ និងអនុវត្តការគាំពារជីវភាពមន្ត្រីរាជការ ក៏ដូចជាមន្ត្រីចូលនិវត្តន៍ ទៅតាមលទ្ធភាព ដើម្បីធានាឱ្យបាននូវភាពរឹងមាំនៃស្មារតីសាមគ្គីភាព ភាតរភាព មិត្តភាព ឯកភាពផ្ទៃក្នុង និងបរិយាកាសការងារមួយ ប្រកបដោយភាពកក់ក្តៅ មានជំនឿទុកចិត្តគ្នា និងចេះរួមសុខរួមទុក្ខជាមួយគ្នា
- កែសម្រួលរចនាសម្ព័ន្ធគ្រប់គ្រង តាមរយៈអនុក្រឹត្យលេខ១៣៥ អនក្រ.បក ចុះថ្ងៃទី០៥ ខែកក្កដា ឆ្នាំ២០១៦ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងបរិស្ថាន ដើម្បីឆ្លើយតបទៅនឹងវិសាលភាពការងារ ស្របតាមការវិវត្តនៃបរិបទសង្គមកម្ពុជា តំបន់ និងពិភពលោក ក៏ដូចជាដើម្បីឆ្លើយតបនឹងគោលដៅជាសារវន្តនៃកំណែទម្រង់ស៊ីជម្រៅនិងគ្រប់ជ្រុងជ្រោយរបស់រាជរដ្ឋាភិបាល ជាពិសេសកំណែទម្រង់មុខងារសាធារណៈ និងកំណែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ
- កសាង និងពង្រឹងសមត្ថភាពមន្ត្រីរាជការ ដើម្បីពង្រឹងប្រសិទ្ធភាពការងារ ទាំងកិច្ចការរដ្ឋបាល ហិរញ្ញវត្ថុ និងការងារជំនាញ ឱ្យស្របតាមរបៀបរបបការងារ ដែលត្រូវបានកែសម្រួល តាមគោលការណ៍ «សមូហភាពដឹកនាំ បុគ្គលទទួលខុសត្រូវ»
- បំពាក់មធ្យោបាយ សម្ភារៈ និងបរិក្ខារចំបាច់នានា ជាអាទិ៍ «អគារមរតកតេជោ» ជាទីស្តីការថ្មីរបស់ក្រសួង រថយន្ត ទោចក្រយានយន្ត កុំព្យូទ័រ ម៉ាស៊ីនព្រីន គ្រឿងសង្ហារឹម ។ល។ ដើម្បីសម្រួលដល់ការបំពេញភារកិច្ចរបស់ថ្នាក់ដឹកនាំ និងមន្ត្រីរាជការ
- ពង្រឹងការអនុវត្តច្បាប់ និងលិខិតបទដ្ឋានគតិយុត្តិពាក់ព័ន្ធ ក៏ដូចជាជំរុញការផ្ទេរមុខងារទៅឱ្យរដ្ឋបាលថ្នាក់ក្រោមជាតិ ស្របតាមគោលនយោបាយ និងកម្មវិធីកំណែទម្រង់វិមជ្ឈការ និងវិសហមជ្ឈការ
- ចាប់ផ្តើមអនុវត្តថវិកាតាមកម្មវិធី ចាប់តាំងពីដើមឆ្នាំ២០១៦ ដោយបានបង្កើតឱ្យមានអង្គភាពថវិកាចំនួន ៣០ សំដៅបង្កើនប្រសិទ្ធភាព និងប្រសិទ្ធផលនៃការប្រើប្រាស់កញ្ចប់ថវិកា ដើម្បីជំរុញការអនុវត្តកម្មវិធីកំណែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ ដំណាក់កាលទី៣
- រៀបចំ «ក្រមបរិស្ថាន» ដែលមានវិសាលភាពគ្របដណ្តប់លើការងារពាក់ព័ន្ធនឹងវិស័យបរិស្ថាន និងធនធានធម្មជាតិ ដោយការធ្វើសមាហរណកម្មច្បាប់ និងលិខិតបទដ្ឋានគតិយុត្តពាក់ព័ន្ធដែលមានស្រាប់

- រៀបចំ «យុទ្ធសាស្ត្រ និងផែនការសកម្មភាពបរិស្ថានជាតិ ឆ្នាំ២០១៦-២០២៣» សម្រាប់ជាត្រីវិស័យតម្រង់ទិសដល់ការងារគាំពារបរិស្ថាន ការគ្រប់គ្រងធនធានធម្មជាតិ ការអភិរក្សជីវៈចម្រុះ និងការអភិវឌ្ឍដោយចីរភាព ដោយសហការជាមួយក្រសួង ស្ថាប័ន និងដៃគូពាក់ព័ន្ធ។

**២. កិច្ចគាំពារបរិស្ថាន៖** ដើម្បីពង្រឹងការងារគ្រប់គ្រងគុណភាពបរិស្ថាន សំដៅរក្សាបាននូវបរិស្ថានល្អស្អាត ក្រសួងបរិស្ថានបាននិងកំពុងផ្តោតការយកចិត្តទុកដាក់លើការងារជាអាទិភាពដូចខាងក្រោម៖

- រៀបចំលិខិតបទដ្ឋានគតិយុត្តចាំបាច់មួយចំនួនបន្ថែមទៀត ដូចជា សេចក្តីព្រាងអនុក្រឹត្យស្តីពីការគ្រប់គ្រងប្រព័ន្ធលូ និងប្រព័ន្ធប្រព្រឹត្តកម្មទឹកកខ្វក់ សេចក្តីព្រាងអនុក្រឹត្យស្តីពីការគ្រប់គ្រងថង់ប្លាស្ទិក និងសេចក្តីព្រាងច្បាប់ស្តីពីការវាយតម្លៃហេតុប៉ះពាល់បរិស្ថាន
- រៀបចំគោលការណ៍ណែនាំ និងលិខិតបទដ្ឋានគតិយុត្ត សម្រាប់ជំរុញការអនុវត្តអនុក្រឹត្យស្តីពីការគ្រប់គ្រងសំរាម សំណល់រឹងទីប្រជុំជន អនុក្រឹត្យស្តីពីការគ្រប់គ្រងសំណល់បរិក្ខារអគ្គិសនី និងអេឡិចត្រូនិក និងអនុក្រឹត្យស្តីពីការបង្កើតមូលនិធិបរិស្ថាន និងសង្គម
- រៀបចំសេចក្តីព្រាងគោលនយោបាយ និងផែនការយុទ្ធសាស្ត្រស្តីពីការគ្រប់គ្រងគុណភាពខ្យល់ និងផែនការយុទ្ធសាស្ត្រស្តីពីការគ្រប់គ្រងសំណល់ ដើម្បីពង្រឹងប្រសិទ្ធភាពនៃការគ្រប់គ្រងសំណល់គ្រប់ប្រភេទ តាមបែបវិធីសាស្ត្រចម្រុះ ស្របតាមទស្សនាទាន «ការអភិវឌ្ឍទីក្រុងដោយនិរន្តរភាព»
- ជំរុញការប្រើប្រាស់ «**កញ្ចប់ថវិកាសេវាអនាម័យបរិស្ថាន**» សម្រាប់អន្តរាគមន៍លើការងារគ្រប់គ្រងសំណល់រឹង រាវ តាមក្រុងគោលដៅទាំង ២៦ ឱ្យមានប្រសិទ្ធភាព និងគណនេយ្យភាព ព្រមទាំងពិនិត្យលទ្ធភាពបង្កើនកញ្ចប់ថវិកានេះ ដោយសហការយ៉ាងជិតស្និទ្ធជាមួយក្រសួងមហាផ្ទៃ និងក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ។ ក្នុងឆ្នាំ២០១៥ ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ បានផ្តល់កញ្ចប់ថវិកាសេវាអនាម័យបរិស្ថាននូវទឹកប្រាក់ចំនួន ៥.០០០ លានរៀល ហើយសម្រាប់ឆ្នាំ២០១៦ កញ្ចប់ថវិកានេះត្រូវបានបង្កើនដល់ចំនួន ៨.០០០ លានរៀល ហើយក្រសួងសង្ឃឹមថា ក្នុងឆ្នាំ២០១៧ កញ្ចប់ថវិកានេះនឹងត្រូវបង្កើនបន្ថែមទៀត។
- បង្កើនសកម្មភាពពិនិត្យ ផ្តល់យោបល់ និងឆ្លងលើរបាយការណ៍វាយតម្លៃហេតុប៉ះពាល់បរិស្ថាន និងសង្គម ដោយបានបង្កើតក្រុមការងារចំនួន ៣ បន្ថែមទៀត និងបង្កើនសកម្មភាពចុះអង្កេតតាមដាននូវការអនុវត្តផែនការគ្រប់គ្រងបរិស្ថាន និងកិច្ចសន្យាការពារបរិស្ថាន
- បង្កើន និងពង្រឹងសកម្មភាពចុះត្រួតពិនិត្យ តាមដាន និងធ្វើអធិការកិច្ចជាប្រចាំនូវការបំពុលបរិស្ថាននានា រួមមាន៖ ការបំពុលទឹក ដី ខ្យល់ និងការរំខានដោយសំឡេង នៅតាមប្រភពបំពុល
- ពង្រឹង និងពង្រីកសមត្ថភាពការងារមន្ទីរពិសោធន៍ សំដៅធានាសុក្រិតភាពនៃការវិភាគ និងការព្យាករណ៍កម្រិតគ្រោះថ្នាក់នៃការបំពុល ដែលការងារនេះត្រូវការគាំទ្រផ្នែកហិរញ្ញវត្ថុ សម្រាប់បំពាក់បន្ថែមនូវឧបករណ៍ពិសោធន៍ចាំបាច់នានា និងសម្រាប់បណ្តុះបណ្តាលធនធានមនុស្សបន្ថែមទៀត។

**៣. ការងារគ្រប់គ្រងធនធានធម្មជាតិ និងការអភិរក្សជីវៈចម្រុះ៖** ដើម្បីពង្រឹងការការពារ និងអភិរក្សធនធានធម្មជាតិ ក្រសួងបរិស្ថានបាននិងកំពុងផ្តោតការយកចិត្តទុកដាក់លើការងារជាអាទិភាពដូចខាងក្រោម៖

- រៀបចំច្បាប់ និងលិខិតបទដ្ឋានគតិយុត្តិចាំបាច់នានាបន្ថែមទៀត ដើម្បីពង្រឹងប្រសិទ្ធភាពការងារគ្រប់គ្រង ទប់ស្កាត់ និងបង្ក្រាបបទល្មើសធនធានធម្មជាតិ
- អនុវត្តសេចក្តីសម្រេចរបស់រាជរដ្ឋាភិបាល ក្នុងការផ្ទេរគម្រោងវិនិយោគអភិវឌ្ឍន៍សម្បទានដីសេដ្ឋកិច្ចចំនួន ៧៣ ពីក្រសួងបរិស្ថាន ទៅឱ្យក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ និងផ្ទេរតំបន់ព្រៃការពារចំនួន ១៣កន្លែង និងព្រៃផ្តល់ផលចំនួន ៥កន្លែង ពីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ មកក្រសួងបរិស្ថាន
- រៀបចំបញ្ចូលតំបន់ព្រៃការពារ និងព្រៃផ្តល់ចំនួន ១៨កន្លែង ដែលបានផ្ទេរមកពីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ទៅជាតំបន់ការពារធម្មជាតិ និងបានបង្កើតតំបន់ការពារធម្មជាតិថ្មីចំនួន ៣

បន្ថែមទៀត ដែលធ្វើឱ្យតំបន់ការពារធម្មជាតិសរុបកើនឡើងដល់ចំនួន ៤៥ គ្របដណ្ដប់លើផ្ទៃដីប្រមាណ ៦លានហិកតា។ ដូច្នេះ ដើម្បីធានាបាននូវប្រសិទ្ធភាពក្នុងការគ្រប់គ្រងតំបន់ការពារធម្មជាតិទាំងនេះ ក្រសួងបានស្នើសុំរាជរដ្ឋាភិបាលបញ្ចូលមន្ត្រីឧទ្យានុរក្សដែលមានស្រាប់ចំនួន ៩៦០នាក់ទៅក្នុងក្របខណ្ឌមុខងារសាធារណៈ និងផ្ដល់របបហូបចុកដល់មន្ត្រីឧទ្យានុរក្សដែលបំពេញការងារតាមគោលដៅឱ្យបានសមរម្យ។ ទន្ទឹមនឹងនេះ ក្រសួងកំពុងដំណើរការជ្រើសរើសមន្ត្រីឧទ្យានុរក្សថ្មីចំនួន៣០០នាក់បន្ថែមទៀត តាមការអនុញ្ញាតរបស់រាជរដ្ឋាភិបាល។

- ពង្រឹងសមត្ថភាពមន្ត្រីជំនាញ និងមន្ត្រីឧទ្យានុរក្ស ក្នុងការទប់ស្កាត់ និងបង្ក្រាបបទល្មើសធនធានធម្មជាតិគ្រប់ប្រភេទ ក្នុងតួនាទីជាមន្ត្រីនគរបាលយុត្តិធម៌ និងជាភ្នាក់ងារមន្ត្រីនគរបាលយុត្តិធម៌ស្របតាមច្បាប់ស្ដីពីតំបន់ការពារធម្មជាតិ និងនីតិវិធីនៃច្បាប់ជាធរមាន ដើម្បីធានាប្រសិទ្ធភាពការងារគ្រប់គ្រងតំបន់ការពារធម្មជាតិ
- ធ្វើការសិក្សាទៅលើតំបន់មួយចំនួនទៀត ដែលមានសក្ដានុពល ដើម្បីបង្កើតជាតំបន់ការពារធម្មជាតិថ្នាក់ក្រោមជាតិបន្ថែមទៀត ដោយសហការយ៉ាងជិតស្និទ្ធជាមួយគ្រប់ភាគីពាក់ព័ន្ធ ជាពិសេសរដ្ឋបាលថ្នាក់ក្រោមជាតិ
- រៀបចំរចនាសម្ព័ន្ធគ្រប់គ្រងតំបន់ការពារធម្មជាតិនៅថ្នាក់ក្រោមជាតិ ដើម្បីពង្រឹងប្រសិទ្ធភាពការងារទាំងខ្សែបណ្ដោយ និងខ្សែទទឹង តាមរយៈការប្រគល់ភារកិច្ច និងការទទួលខុសត្រូវផ្ទាល់ទៅឱ្យមន្ទីរបរិស្ថាន ក្រោមការដឹកនាំរួមរបស់គណៈបញ្ជាការឯកភាពខេត្ត
- ចូលរួមសហការជាមួយក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ និងក្រសួង ស្ថាប័ន ក្នុងការរៀបចំផែនទីឯកភាព សម្រាប់ការងារគ្រប់គ្រងនិងប្រើប្រាស់ដីធ្លី ដូចជា ដីលំនៅដ្ឋាន សម្បទានដីសេដ្ឋកិច្ច សម្បទានដីសង្គមកិច្ច តំបន់អភិរក្ស និងតំបន់ការពារធម្មជាតិ។ល។
- សិក្សា ប្រមូលទិន្នន័យព័ត៌មានភូមិសាស្ត្រ និងបកប្រែទិន្នន័យពីផ្កាយរណប ដើម្បីធ្វើបច្ចុប្បន្នភាពផែនទីតំបន់ការពារធម្មជាតិឡើងវិញ
- រៀបចំបង្កើតរបៀងអភិរក្សជីវៈចម្រុះ និងផែនការយុទ្ធសាស្ត្រគ្រប់គ្រងតំបន់ការពារធម្មជាតិ សំដៅពង្រឹងប្រសិទ្ធភាពនៃការការពារ និងអភិរក្សធនធានធម្មជាតិ
- រៀបចំកំណត់តំបន់ និងរៀបចំផែនការគ្រប់គ្រង ក៏ដូចជាការបោះបង្គោលព្រំប្រទល់តំបន់ការពារធម្មជាតិឱ្យបានច្បាស់លាស់

**៤. ការងារគ្រប់គ្រង និងអភិវឌ្ឍន៍សហគមន៍មូលដ្ឋាន៖** ដើម្បីលើកកម្ពស់ជីវភាពប្រជាសហគមន៍ និងជំរុញការចូលរួមរបស់សហគមន៍ក្នុងការការពារ និងអភិរក្សធនធានធម្មជាតិ ក្រសួងបរិស្ថានបាននិងកំពុងផ្ដោតការយកចិត្តទុកដាក់លើការងារជាអាទិភាពដូចខាងក្រោម៖

- បង្កើនការយកចិត្តទុកដាក់លើកកម្ពស់តួនាទី និងពង្រឹងសមត្ថភាពរបស់សហគមន៍មូលដ្ឋាន ក្នុងតំបន់ការពារធម្មជាតិ ដើម្បីជំរុញការចូលរួមរបស់សហគមន៍ក្នុងការគ្រប់គ្រងតំបន់ការពារធម្មជាតិ ក៏ដូចជាជួយលើកកម្ពស់ជីវភាពរស់នៅរបស់ពួកគាត់ ជាពិសេសរបស់បងប្អូនជនជាតិដើមភាគតិចតាមរយៈការកែលម្អមុខរបរចិញ្ចឹមជីវិត ជាអាទិ៍ ការបង្កបង្កើនផល ក៏ដូចជាការផ្ដល់សេវាកម្មទេសចរណ៍ធម្មជាតិ ប្រវត្តិសាស្ត្រ និងវប្បធម៌
- រៀបចំគម្រោងសាកល្បងអភិវឌ្ឍន៍សហគមន៍តំបន់ការពារធម្មជាតិ ដោយប្រើប្រាស់កញ្ចប់ថវិកាប្រមាណ ១៣ពាន់លានរៀល ដែលរាជរដ្ឋាភិបាលទើបសម្រេចផ្ដល់ជូន សំដៅលើកកម្ពស់ជីវភាពរបស់ប្រជាសហគមន៍ ក៏ដូចជាកាត់បន្ថយការពឹងអាស្រ័យលើផល និងអនុផលព្រៃឈើ និងការប្រមាញ់សត្វ

- ពង្រឹងការគ្រប់គ្រងសហគមន៍តំបន់ការពារធម្មជាតិ ដែលមានស្រាប់ចំនួន ១៣៩សហគមន៍ គ្របដណ្តប់លើផ្ទៃដីប្រមាណ ១៨២.៩៩៣ ហិកតា និងមានសមាជិកចំនួន ៣០.៧០១ គ្រួសារ រស់នៅក្នុងភូមិចំនួន ២៣៥ភូមិ
- រៀបចំបង្កើតសហគមន៍តំបន់ការពារធម្មជាតិថ្មីៗបន្ថែមទៀត សម្រាប់ប្រជាសហគមន៍រស់នៅក្នុង និងជាប់តំបន់ការពារធម្មជាតិ
- ពិនិត្យ និងវាយតម្លៃឡើងវិញនូវការអនុវត្តគម្រោងវិនិយោគអភិវឌ្ឍន៍ទេសចរធម្មជាតិរបស់ក្រុមហ៊ុនឯកជន នៅក្នុងតំបន់ការពារធម្មជាតិ ដែលជាលទ្ធផលរាជរដ្ឋាភិបាលបានសម្រេចនិរាករណ៍គម្រោងវិនិយោគរបស់ក្រុមហ៊ុន HONG KONG ASIA RESEARCH INVESTMENT AND DEVELOPMENT CONSULTING GROUP CO., LTD
- ពង្រឹងការគ្រប់គ្រងសហគមន៍ទេសចរធម្មជាតិ តាមរយៈការផ្តល់ការគាំទ្រផ្នែកបច្ចេកទេស និងជួយដោះស្រាយបញ្ហាប្រឈមនានា ដែលជាក់ស្តែងបានជួយដោះស្រាយបញ្ចប់បញ្ហាទំនាស់ដីធ្លីនៅសហគមន៍ចំបក់ ដែលបានអូសបន្លាយជិត២០ឆ្នាំ
- សិក្សាកំណត់សក្តានុពលរបស់សហគមន៍តំបន់ការពារធម្មជាតិនានា ដើម្បីជំរុញការរៀបចំគម្រោងអភិវឌ្ឍន៍សហគមន៍ទេសចរធម្មជាតិ ក៏ដូចជារៀបចំបង្កើតរបៀងទេសចរធម្មជាតិជាលក្ខណៈប្រព័ន្ធ
- សិក្សា និងរៀបចំបង្កើតតំបន់បេតិកភណ្ឌធម្មជាតិថ្មីៗបន្ថែមទៀត និងកំណត់តំបន់ការពារធម្មជាតិជុំវិញប្រាសាទ និងបុរាណស្ថានក្នុងតំបន់ការពារធម្មជាតិនានា។

**៥. ការងារអប់រំ និងផ្សព្វផ្សាយព័ត៌មានបរិស្ថាន៖** ដើម្បីលើកកម្ពស់ការយល់ដឹងជាសាធារណៈអំពីកិច្ចគាំពារបរិស្ថាន ការគ្រប់គ្រងធនធានធម្មជាតិ ការអភិរក្សជីវៈចម្រុះ និងការអភិវឌ្ឍដោយចីរភាព ក្រសួងបរិស្ថានបាននិងកំពុងផ្តោតការយកចិត្តទុកដាក់លើការងារជាអាទិភាពដូចខាងក្រោម៖

- រៀបចំសេចក្តីព្រាងប្រកាសស្តីពីស្តង់ដាមេត្រីភាពបរិស្ថាន ដើម្បីលើកទឹកចិត្តឱ្យមានការចូលរួមពីសាធារណជនក្នុងការប្រតិបត្តិបៃតង និងមេត្រីភាពបរិស្ថាន
- រៀបចំសេចក្តីព្រាងអនុក្រឹត្យស្តីពីស្លាកសញ្ញាបៃតង (Eco-Label) ក្នុងគោលបំណងដើម្បីកំណត់និងផ្តល់នូវស្លាកសញ្ញាបៃតងទៅលើផលិតផល និងសេវាកម្មផ្សេងៗ សំដៅលើកកម្ពស់សុវត្ថិភាព និងគុណភាពនៃផលិតផល និងសេវាកម្ម
- ពង្រឹងការងារអប់រំបណ្តុះបណ្តាលបរិស្ថានទាំងក្នុងប្រព័ន្ធ និងក្រៅប្រព័ន្ធ និងផ្សព្វផ្សាយព័ត៌មានបរិស្ថាន ដោយបានសហការយ៉ាងជិតស្និទ្ធជាមួយគ្រប់ភាគីពាក់ព័ន្ធ
- សហការជាមួយក្រសួងអប់រំ យុវជន និងកីឡា ដើម្បីបង្កើតក្រុមការងារ សម្របសម្រួលកិច្ចសហប្រតិបត្តិការរវាងក្រសួងទាំងពីរ ក្នុងក្របខណ្ឌការងារអប់រំ ការបណ្តុះបណ្តាលជំនាញ ការសិក្សាស្រាវជ្រាវ និងការផ្តល់សេវាពិគ្រោះយោបល់លើវិស័យបរិស្ថាន ជាពិសេស ការបញ្ចូលការអប់រំបរិស្ថានទៅក្នុងកម្មវិធីសិក្សានៅតាមគ្រឹះស្ថានសិក្សាគ្រប់កម្រិត។ ជាងនេះទៅទៀត ក្រសួងក៏បានសហការបញ្ចូលការអប់រំបរិស្ថាន ស្តីពីការអភិវឌ្ឍដោយចីរភាពទៅក្នុងកម្មវិធីសិក្សានៅវិទ្យាស្ថានជាតិអប់រំ ដើម្បីឱ្យគរុសិស្សទាំងអស់មានមូលដ្ឋានចំណេះដឹងលើវិស័យបរិស្ថាន។
- ជំរុញការអនុវត្តកម្មវិធីសាលាមេត្រីភាពបរិស្ថាននៅតាមសាលារៀននានា ដើម្បីឱ្យសិស្សានុសិស្សមានការយល់ដឹងអំពីគុណប្រយោជន៍នៃការប្រតិបត្តិបរិស្ថាន
- បង្កើនការផ្សព្វផ្សាយព័ត៌មានបរិស្ថាន តាមប្រព័ន្ធផ្សព្វផ្សាយព័ត៌មាននានា រួមមានវិទ្យុ ទូរទស្សន៍ កាសែត ទស្សនាវដ្តី ខិត្តបណ្ណ ប្រព័ន្ធទំនាក់ទំនងសង្គមហ្វេសប៊ុក និងគេហទំព័រជាដើម ក្នុងគោលបំណងបញ្ជ្រាបព័ត៌មានបរិស្ថាន និងលើកកម្ពស់ការយល់ដឹងអំពីបរិស្ថានដល់សាធារណជន សំដៅកែប្រែទម្លាប់ និងផ្នត់គំនិតរបស់សាធារណជនឱ្យមានឥរិយាបថល្អចំពោះបរិស្ថាន

- ពិនិត្យ វាយតម្លៃ ផ្តល់រង្វាន់ និងលើកទឹកចិត្តដល់បុគ្គល វិស័យសាធារណៈ វិស័យឯកជន សង្គមស៊ីវិល ដែលមានស្នាដៃក្នុងការអនុវត្តទម្លាប់ល្អខាងប្រតិបត្តិការបៃតង ឬ មេត្រីភាពបរិស្ថាន ដើម្បីលើកទឹកចិត្តនិងជំរុញឱ្យមានការចូលរួម ពីអ្នកពាក់ព័ន្ធទាំងអស់ក្នុងកិច្ចគាំពារបរិស្ថាន ការគ្រប់គ្រងធនធានធម្មជាតិ ការអភិរក្សជីវៈចម្រុះ និងការអភិវឌ្ឍដោយចីរភាព
- ធ្វើបច្ចុប្បន្នភាពផែនទីតំបន់ការពារធម្មជាតិទាំង៤៥ សម្រាប់សម្រួលដល់ការគ្រប់គ្រងតំបន់ការពារធម្មជាតិ ក៏ដូចជាសម្រាប់ជាមូលដ្ឋានក្នុងការរៀបចំបង្កើតរបៀងអភិរក្សជីវចម្រុះ ដើម្បីរក្សាបានមុខងារ និងសេវាកម្មប្រព័ន្ធអេកូឡូស៊ី
- រៀបចំបង្កើតផែនទីប្រព័ន្ធអេកូឡូស៊ីចម្រុះ ដើម្បីកសាងប្រព័ន្ធគាំទ្រសេចក្តីសម្រេចចិត្តសំដៅជួយសម្រួលដល់ការប្រើប្រាស់ដីប្រកបដោយចីរភាព
- ផ្តួចផ្តើមរៀបចំឱ្យមានគេហទំព័រចែករំលែកទិន្នន័យបរិស្ថាន ដើម្បីប្រមូលផ្តុំទិន្នន័យពាក់ព័ន្ធនឹងវិស័យបរិស្ថាន និងធនធានធម្មជាតិ និងប្រើប្រាស់សម្រាប់ការសិក្សា ស្រាវជ្រាវ និងការរៀបចំគោលនយោបាយ
- សហការជាមួយគ្រប់ក្រសួង ស្ថាប័ន និងអ្នកពាក់ព័ន្ធ ក្នុងការប្រមូលទិន្នន័យពាក់ព័ន្ធនឹងកិច្ចគាំពារបរិស្ថាន ការអភិរក្សជីវៈចម្រុះ និងធនធានធម្មជាតិ ដើម្បីកសាងរបាយការណ៍ស្តីពីស្ថានភាពបរិស្ថានជាតិ ដែលជាមូលដ្ឋានដ៏សំខាន់ សម្រាប់ការរៀបចំគោលនយោបាយ និងយុទ្ធសាស្ត្របរិស្ថានជាតិ
- បង្កើតបណ្ណាល័យអេឡិកត្រូនិក (E-Library) ដើម្បីរក្សាទុកឯកសារព័ត៌មាន និងឯកសារពាក់ព័ន្ធនឹងបរិស្ថាន ហើយភ្ជាប់ជាមួយបណ្ណាល័យអេឡិកត្រូនិកនៃសាកលវិទ្យាល័យដទៃទៀត ដែលអាចឱ្យសាធារណៈជនងាយស្រួលក្នុងការចូលទៅកាន់ឯកសារផ្សេងៗ

៦. **ការអភិវឌ្ឍដោយចីរភាព៖** ដើម្បីធានាការអភិវឌ្ឍ ដែលមានតុល្យភាពរវាងបរិស្ថាន សេដ្ឋកិច្ច សង្គម និងវប្បធម៌ ក្រុមប្រឹក្សាជាតិអភិវឌ្ឍន៍ដោយចីរភាពបាននិងកំពុងផ្តោតការយកចិត្តទុកដាក់លើការងារជាអាទិភាពដូចខាងក្រោម៖

- សម្របសម្រួលការផ្តល់សច្ចាប័នលើពិធីសារណាហ្គោយ៉ា (Nagoya Protocol) ស្តីពីការប្រើប្រាស់ និងការបែងចែកផលប្រយោជន៍ពីធនធានពន្ធុ កិច្ចព្រមព្រៀងស្តីពីការបង្កើតមជ្ឈមណ្ឌលជីវៈចម្រុះអាស៊ាន និងកិច្ចព្រមព្រៀងទីក្រុងប៉ារីសស្តីពីការប្រែប្រួលអាកាសធាតុ
- ជំរុញការអនុវត្តផែនការយុទ្ធសាស្ត្រជាតិឆ្លើយតបនឹងការប្រែប្រួលអាកាសធាតុកម្ពុជា ២០១៤-២០២៣
- សម្របសម្រួលការរៀបចំ និងអនុវត្តផែនការយុទ្ធសាស្ត្រ និងផែនការសកម្មភាពឆ្លើយតបនឹងការប្រែប្រួលអាកាសធាតុតាមវិស័យរបស់ក្រសួង ស្ថាប័ន ចំនួន១៤
- រៀបចំផែនការយុទ្ធសាស្ត្រ «ទីក្រុងបៃតង» សម្រាប់រាជធានីភ្នំពេញ ឆ្នាំ២០១៦-២០២៥
- រៀបចំយុទ្ធសាស្ត្រ និងផែនការជាតិស្តីពីជីវៈចម្រុះ និងរបាយការណ៍ស្តីពីស្ថានភាពជីវៈចម្រុះ
- រៀបចំសេចក្តីព្រាងយុទ្ធសាស្ត្ររេដបូក (REDD+) ជាតិ ដើម្បីកៀរគរធនធានសម្រាប់លើកកម្ពស់កិច្ចការពារព្រៃឈើ
- រៀបចំឯកសារទស្សនាទាន សម្រាប់ការតាក់តែងគោលនយោបាយស្តីពី «ការបង់ថ្លៃសេវាកម្មប្រព័ន្ធអេកូឡូស៊ី»
- រៀបចំឯកសារទស្សនាទានស្តីពី «កិច្ចសហប្រតិបត្តិការត្បូង-ត្បូងស្តីពីការប្រែប្រួលអាកាសធាតុ» ជាមួយសាធារណរដ្ឋប្រជាមានិតចិន
- សម្របសម្រួលកិច្ចសហប្រតិបត្តិការរវាងកម្ពុជា-រុស្ស៊ី ក្នុងការប្រើប្រាស់បច្ចេកវិទ្យានុយក្លេអ៊ែរសម្រាប់បម្រើឱ្យគោលបំណងសន្តិភាព ក្នុងវិស័យវេជ្ជសាស្ត្រ កសិកម្ម និងឧស្សាហកម្ម
- ចុះហត្ថលេខាលើកិច្ចព្រមព្រៀងក្របខ័ណ្ឌស្តីពីការបង្កើត «សម្ព័ន្ធភាពថាមពលព្រះអាទិត្យអន្តរជាតិ» (International Solar Alliance)

- សិក្សាសមិទ្ធិលទ្ធភាពនៃការផ្គត់ផ្គង់អគ្គិសនី ពីប្រភពថាមពលកកើតឡើងវិញ
- សម្របសម្រួលការអនុវត្តគម្រោងឥណទានកាបូនរួមគ្នាជាមួយភាគីជប៉ុន ជាពិសេសគម្រោងតម្លើងអំពូល LED នៅរាជធានីភ្នំពេញ និងខេត្តសៀមរាប

សមិទ្ធផលទាំងនេះគឺបានមកពីការប្ដេជ្ញាចិត្ត និងការខិតខំប្រឹងប្រែងបំពេញភារកិច្ចរបស់ថ្នាក់ដឹកនាំ និងមន្ត្រីរាជការគ្រប់លំដាប់ថ្នាក់នៃក្រសួងបរិស្ថាន និងក្រុមប្រឹក្សាជាតិអភិវឌ្ឍន៍ដោយចីរភាព ដែលនេះឆ្លុះបញ្ចាំងឱ្យឃើញនូវស្មារតីទទួលខុសត្រូវខ្ពស់ និងភាពជាម្ចាស់លើកិច្ចដ៏សំខាន់ទាំងអស់នេះ។ ទោះបីជាយ៉ាងនេះក្ដី លទ្ធផលការងារទាំងនេះមិនអាចសម្រេចបានដោយមិនមានការចូលរួមសហការពីសំណាក់ក្រសួង ស្ថាប័នពាក់ព័ន្ធ រដ្ឋបាលថ្នាក់ក្រោមជាតិ អង្គភាពជុំវិញខេត្ត ដៃគូអភិវឌ្ឍន៍ អង្គការសង្គមស៊ីវិល វិស័យឯកជន និងប្រជាសហគមន៍មូលដ្ឋាននោះឡើយ។

- *ឯកឧត្តមឧបនាយករដ្ឋមន្ត្រីជាទីគោរពដ៏ខ្ពង់ខ្ពស់!*
- *ឯកឧត្តម លោកជំទាវ លោក លោកស្រី និងអង្គពិធីទាំងមូលជាទីគោរពរាប់អាន!*

ក្នុងដំណើរការនៃសន្និបាតរយៈពេលបីថ្ងៃនេះ ក្រសួងបានរៀបចំសិក្ខាសាលាបច្ចេកទេសចំនួន៥ ក្រោមប្រធានបទខុសៗគ្នា ទៅតាមអង្គភាពចំណុះក្រសួង ដើម្បីត្រួតពិនិត្យ និងវាយតម្លៃលទ្ធផលការងារទៅតាមជំនាញ ក៏ដូចជាការប្រមូលផ្ដុំគំនិត ទស្សនៈ មតិយោបល់ តាមរយៈការបើកឱ្យមានកិច្ចពិភាក្សា ផ្លាស់ប្ដូរព័ត៌មាន ចំណេះដឹង មេរៀន និងបទពិសោធ រវាងមន្ត្រីជំនាញ អ្នកស្រាវជ្រាវ ប្រតិបត្តិករ និងភាគីពាក់ព័ន្ធនានា ហើយទន្ទឹមនឹងនោះ នឹងលើកទិសដៅការងារសម្រាប់បន្តអនុវត្តក្នុងឆ្នាំ២០១៧ខាងមុខនេះ។ ប្រធានបទនៃសិក្ខាសាលាទាំង៥នោះរួមមាន៖ ទី១. សិក្ខាសាលាស្ដីពីការគ្រប់គ្រងការអភិវឌ្ឍដោយចីរភាព ទី២. សិក្ខាសាលាស្ដីពីការគ្រប់គ្រងតំបន់ការពារធម្មជាតិ ទី៣. សិក្ខាសាលាស្ដីពីកិច្ចគាំពារបរិស្ថាន ទី៤. សិក្ខាសាលាស្ដីពីការគ្រប់គ្រងចំណេះដឹង និងផ្សព្វផ្សាយព័ត៌មានបរិស្ថាន និងទី៥. សិក្ខាសាលាស្ដីពីការពង្រឹងអភិបាលកិច្ចល្អ។ ដើម្បីឱ្យសិក្ខាសាលាទាំង៥ ប្រព្រឹត្តទៅប្រកបដោយភាពរលូន និងសម្រេចបានលទ្ធផលជាផ្លែផ្កា ខ្ញុំសូមឱ្យមន្ត្រីរាជការទាំងកម្រិតគោលនយោបាយ និងបច្ចេកទេសមកពីគ្រប់ក្រសួង ស្ថាប័ន និងភាគីពាក់ព័ន្ធ មេត្តាចូលរួមពិភាក្សា និងចែករំលែកបទពិសោធឱ្យបានផុលផុស និងស៊ីជម្រៅលើការងារជំនាញទាំងនេះ។

មុននឹងបញ្ចប់ ក្នុងនាមថ្នាក់ដឹកនាំ និងមន្ត្រីរាជការនៃក្រសួងបរិស្ថាន ខ្ញុំបាទសូមយកឱកាសនេះ ថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅជាថ្មីម្ដងទៀតចំពោះវត្តមានដ៏ខ្ពង់ខ្ពស់របស់ **ឯកឧត្តមឧបនាយករដ្ឋមន្ត្រី ប៊ិន ឈិន** តំណាងដ៏ខ្ពង់ខ្ពស់ **សម្ដេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា** ឯកឧត្តម លោកជំទាវ លោក លោកស្រី ដែលបានចំណាយពេលវេលាដ៏មមាញឹកអញ្ជើញចូលរួមក្នុងពិធីដ៏មានសារៈសំខាន់នាពេលនេះ ហើយខ្ញុំបាទក៏សូមថ្លែងអំណរគុណដល់គ្រប់ក្រសួង ស្ថាប័ន រដ្ឋបាលថ្នាក់ក្រោមជាតិ ដៃគូអភិវឌ្ឍន៍ វិស័យឯកជន សហគមន៍មូលដ្ឋាន និងអ្នកពាក់ព័ន្ធទាំងអស់ ដែលបានផ្ដល់កិច្ចសហការយ៉ាងជិតស្និទ្ធជាមួយក្រសួងបរិស្ថាន ក្នុងបុព្វហេតុបរិស្ថាន ពោលគឺរួមគ្នាកសាងសង្គមកម្ពុជាមួយ ប្រកបដោយបរិស្ថានល្អស្អាត ស្រស់បំព្រង សុខុមាលភាពសង្គម តុល្យភាពនៃប្រព័ន្ធអេកូឡូស៊ី និងការអភិវឌ្ឍដោយចីរភាព។

ជាទីបញ្ចប់ ក្នុងឱកាសឆ្នាំថ្មីដែលនឹងឈានចូលមកដល់ក្នុងពេលឆាប់ៗនេះ ខ្ញុំបាទសូមគោរពជូនពរ **ឯកឧត្តមឧបនាយករដ្ឋមន្ត្រី** ឯកឧត្តម លោកជំទាវ លោក លោកស្រី សមាជិក សមាជិកា នៃអង្គពិធីទាំងមូល សូមប្រកបដោយពុទ្ធពរទាំងបួនប្រការ សុខភាពល្អ និងសុភមង្គលគ្រប់ក្រុមគ្រួសារ ក៏ដូចជាសម្រេចបានជោគជ័យគ្រប់ភារកិច្ចជូនជាតិមាតុភូមិ។

ខ្ញុំបាទសូមគោរពអញ្ជើញ **ឯកឧត្តមឧបនាយករដ្ឋមន្ត្រី** មេត្តាថ្លែងសុន្ទរកថាគន្លឹះបើក «សន្និបាតបូកសរុបលទ្ធផលការងារបរិស្ថានឆ្នាំ២០១៦ និងទិសដៅការងារឆ្នាំ២០១៧» ដោយសេចក្ដីអនុគ្រោះ។

*សូមអរគុណ!*